# អនុស្សរណៈ
# រវាង
# អង្គការ KIDSHELP KAMBODSCHA E.V
# និង
# រាជរដ្ឋាភិបាលកម្ពុជា

*******

## ផ្នែកទី មួយ
## បុព្វកថា

"ដោយយល់ថា" រាជរដ្ឋាភិបាលកម្ពុជាមានបំណងឲ្យអង្គការមិនមែនរដ្ឋាភិបាលបរទេសឈ្មោះ **Kidshelp Kambodscha e.V** ធ្វើសកម្មភាពមនុស្សធម៌ ដើម្បីសុខុមាលភាពសង្គម និងផលប្រយោជន៍សាធារណៈដោយធ្វើសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជា និង

"ដោយយល់ថា" អង្គការ **Kidshelp Kambodscha e.V** មានទីស្នាក់ការនៅ**សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់** និងមានការិយាល័យកណ្ដាលនៅខេត្ត**កណ្ដាល** ជាអង្គការមនុស្សធម៌មិនធ្វើអាជីវកម្មយកចំណេញ ដូចមានចែងនៅក្នុងឯកសារនៃសេចក្ដីប្រកាសបេសកកម្មទិសដៅ និងកម្មវិធីរបស់អង្គការនេះ។

"ដោយយល់ថា" អង្គការ **Kidshelp Kambodscha e.V** យល់ព្រមអនុវត្តតាមច្បាប់ និងបទបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។ ស្ថិតក្នុងគោលបំណងនៃអនុស្សរណៈនេះ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអង្គការ **Kidshelp Kambodscha e.V** បានព្រមព្រៀងគ្នាដូចតទៅៈ

## ផ្នែកទី ពីរ
## ភាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចដូចតទៅៈ

**ប្រការ ១** :

ទទួលស្គាល់ថាអង្គការ **Kidshelp Kambodscha e.V** ទទួលបានការអនុញ្ញាតឲ្យបើកការិយាល័យនៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា ដើម្បីធ្វើសកម្មភាពមនុស្សធម៌ និងអនុវត្តគម្រោងកម្មវិធី ដែលបានទទួលការអនុញ្ញាតនៅក្នុងក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមលក្ខខណ្ឌនៃអនុស្សរណៈនេះ។

**ប្រការ ២:**

អនុញ្ញាតឲ្យអង្គការ **Kidshelp Kambodscha e.V** អនុវត្តការងារមនុស្សធម៌នៅទីកន្លែងផ្សេងៗឬតាមទីរួមខេត្ត ដោយមានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា ដោយផ្អែកលើអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា និងសមត្ថភាពជំនាញ និងថវិកាដែលអង្គការនេះមាន។

**ប្រការ ៣:**

ផ្តល់ជូនប័ណ្ណសំគាល់ខ្លួនដល់បុគ្គលិកបរទេស ដែលទទួលបានលិខិតអនុញ្ញាតឲ្យធ្វើការងារពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្របតាមច្បាប់ និងបទបញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែអ្នកដែលទទួលបានទិដ្ឋាការការទូត ទិដ្ឋាការផ្លូវការ និងទិដ្ឋាការបោរីភាព។ ពាក្យថា "បុគ្គលិកបរទេស" គឺរាប់បញ្ចូលទាំងនាយក ឬតំណាងអង្គការប្រចាំប្រទេស បុគ្គលិកបរទេស អ្នកជំនាញ ទីប្រឹក្សា និងអ្នកម៉ៅការបរទេសទាំងអស់ដែលត្រូវបានជ្រើសរើសឲ្យបំពេញមុខងារពិសេសណាមួយផ្អែក តាមទេពកោសល្យជាក់ស្តែង និងជំនាញច្បាស់លាស់។

**ប្រការ ៤:**

អនុញ្ញាតឲ្យបុគ្គលិកបរទេសនៃអង្គការ **Kidshelp Kambodscha e.V** ស្នាក់នៅបណ្តោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីដែលពេលវេលាបំពេញការងារលើសពី០៣(បី) ខែ ហើយការអនុញ្ញាតនោះត្រូវធ្វើឡើងទៅតាមការកំណត់នៃច្បាប់ និងបទបញ្ញត្តិផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៥:**

អនុញ្ញាតឲ្យអង្គការ **Kidshelp Kambodscha e.V** សហការផ្ទាល់ជាមួយអាជ្ញាធរសាធារណៈ និងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំអនុវត្តត្រួតពិនិត្យ និងបូកសរុបវាយតម្លៃគម្រោងកម្មវិធី ។

**ប្រការ ៦:**

ជូនព័ត៌មានដល់អង្គការអំពីច្បាប់ សេចក្តីសម្រេច និងបទបញ្ញត្តិថ្មីៗដែលពាក់ព័ន្ធដល់ការគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាលបរទេស ។

**ប្រការ ៧:**

អនុញ្ញាតឲ្យអង្គការ **Kidshelp Kambodscha e.V** ជួលដី ជួលផ្ទះសាងសង់ ឬ ជួលការិយាល័យ និងអគារសម្រាប់ធ្វើសកម្មភាពមនុស្សធម៌សមស្របតាមច្បាប់ និងបទបញ្ញត្តិក្នុងស្រុក និងជ្រើសរើសបុគ្គលិកកម្ពុជាដោយគោរពតាមវិធាន និងបទបញ្ញត្តិនៃច្បាប់ការងារ ។

**ប្រការ ៨:**

អនុញ្ញាតឲ្យនាំចូលសម្ភារៈប្រើប្រាស់គ្រឿងបរិក្ខារ គ្រឿងចក្រ ដូចបានកំណត់ក្នុងសំណូមពរនៃគម្រោងដែលបានទទួលការអនុញ្ញាតស្របតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ពន្ធ និងអាករលើការនាំចូលទាំងនោះជាបន្ទុករបស់រដ្ឋ ។

ចំពោះសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន និងយានយន្តត្រូវបានអនុញ្ញាតឲ្យនាំចូលតាមរបបនាំចូលបណ្ដោះអាសន្ន ។

**ប្រការ ៩:**

យល់ព្រមឲ្យអង្គការ **Kidshelp Kambodscha e.V** និងបុគ្គលិកបរទេសរបស់ខ្លួនទទួលបាននូវគុណប្រយោជន៍ ដូចអង្គការមិនមែនរដ្ឋាភិបាលបរទេស និងបុគ្គលិកបរទេសដ៏ទៃទៀតដែលបានអនុញ្ញាតឲ្យធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្នុងករណីដែលមានចែងក្នុងប្រការទី១៩ ។

**ប្រការ ១០:**

ផ្ដល់ទិដ្ឋាការចាំបាច់ដោយឥតគិតថ្លៃ ដោយស្ថានបេសកកម្មការទូតកម្ពុជាប្រចាំនៅបរទេសចំពោះបុគ្គលិកបរទេស រួមទាំងសមាជិកគ្រួសាររបស់គេសំរាប់រយៈពេល ០៣ (បី) ខែ ដំបូងនៃការស្នាក់នៅកម្ពុជា ។ រាល់ការបន្តទិដ្ឋាការជាបន្តបន្ទាប់មកទៀតនឹងមិនត្រូវគិតថ្លៃឡើយ ។ សមាជិកគ្រួសាររួមមាន ប្ដីប្រពន្ធ កូន និងឪពុកម្ដាយ ។

## ផ្នែកទី បី

## ភារកិច្ចរបស់អង្គការ Kidshelp Kambodscha e.V

អង្គការ **Kidshelp Kambodscha e.V** មានភារកិច្ចដូចតទៅ :

**ប្រការ ១១:**

ប្រកាន់ជំហរអព្យាក្រឹតចំពោះគណបក្សនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ គោរពទាំងស្រុងនូវច្បាប់ និងបទបញ្ញត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា និងមិនអនុញ្ញាតឲ្យបុគ្គលិករបស់ខ្លួនចូលរួមក្នុងសកម្មភាពទាំងឡាយណាដែលធ្វើឲ្យប៉ះពាល់ដល់សន្តិភាព ស្ថិរភាព និងសណ្ដាប់ធ្នាប់សាធារណៈ ឬបង្កភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ជាតិ ប្រពៃណី ទំនៀមទំលាប់ជាតិរបស់សង្គមកម្ពុជា ។

ចូលរួមតែក្នុងសកម្មភាពណា ដែលបានទទួលការអនុញ្ញាតដើម្បីបំរើសុខុមាលភាពសង្គម និងផលប្រយោជន៍សាធារណៈ។ មិនធ្វើអាជីវកម្មយកចំណេញ មិនចូលរួមគ្រប់សកម្មភាពនយោបាយដោយប្រកាន់ខ្ជាប់នូវទិសដៅមនុស្សធម៌ និងអភិវឌ្ឍន៍សង្គមតែប៉ុណ្ណោះ ។

**ប្រការ ១២:**

អនុវត្តសកម្មភាពទាំងឡាយ និងប្រតិបត្តិកម្មវិធីជំនួយនៅកម្ពុជា តាមកំរិតនៃបុគ្គលិក ធនធាន និងថវិកាដូចបានចែងយ៉ាងលំអិតក្នុងឧបសម្ព័ន្ធនៃអនុស្សរណៈនេះ ។

ធនធាន និងទ្រព្យសម្បត្តិរបស់អង្គការ **Kidshelp Kambodscha e.V** ត្រូវបានមកពីប្រភពស្របច្បាប់នានា និងត្រូវរាយការណ៍ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**ប្រការ ១៣:**

ផ្តល់ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ចម្លងពីឯកសារដើម ដែលផ្ញើទៅម្ចាស់ជំនួយក្នុងអំឡុងពេល ៣០(សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយព្រមទាំងគ្រប់ឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ០១ (មួយ) ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើមឲ្យបានក្នុងអំឡុងពេល៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម។

ក្នុងករណីចាំបាច់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិ អាចធ្វើការត្រួតពិនិត្យ និងធ្វើសវនកម្មលើអង្គការ **Kidshelp Kambodscha e.V** ។

**ប្រការ ១៤:**

ជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីរាល់ព័ត៌មានគណនី ដែលត្រូវបើកសំរាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅក្នុងធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃចុះអនុស្សរណៈនេះ ។

**ប្រការ ១៥:**

ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការ នាយក ឬតំណាងប្រចាំប្រទេស ឬការប្រែប្រួលព័ត៌មានគណនីធនាគារ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃដែលផ្លាស់ប្តូរ ឬប្រែប្រួលដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដែលបានផ្លាស់ប្តូរ ។

ផ្តល់ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នូវបញ្ជីឈ្មោះបច្ចុប្បន្នភាពបុគ្គលិកបរទេស និងបុគ្គលិកក្នុងស្រុក ។

បញ្ជីឈ្មោះត្រូវរាប់បញ្ចូលព័ត៌មានដូចតទៅ:

១. ឈ្មោះ (នាម និងគោត្តនាម)

២. សញ្ជាតិ

៣.លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណ ឬឯកសារផ្សេងទៀតដែលមានតំលៃស្មើគ្នា
៤. មុខតំណែងក្នុងអង្គការមិនមែនរដ្ឋាភិបាលបរទេស
៥. រយៈពេលនៃកិច្ចសន្យាការងារ-លិខិតអនុញ្ញាតឲ្យធ្វើការងារ
៦. ឈ្មោះសមាជិកគ្រួសារផ្ទាល់ដែលនៅក្នុងបន្ទុក និង
៧. អាសយដ្ឋាននៅកម្ពុជា ។

**ប្រការ ១៦:**

ប្រើប្រាស់បុគ្គលិកកម្ពុជាឲ្យបានច្រើននៅគ្រប់ការងារដែលអាចធ្វើបាន ដោយគោរពច្បាប់ការងាររបស់ពួកគេ កាត់បន្ថយឲ្យនៅតិចបំផុតចំនួនបុគ្គលិកបរទេសក្នុងគ្រប់គម្រោង ឬកម្មវិធី និងផ្ទេរចំណេះដឹង និងជំនាញឲ្យបានជាអតិបរិមាដល់បុគ្គលិកកម្ពុជាស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

**ប្រការ ១៧:**

ចៀសវាងការជ្រើសរើសអ្នកទេសចរណ៍ ឬជនបរទេសអន្តោប្រវេសន៍ខុសច្បាប់ឲ្យធ្វើការងារ ទោះបំពេញការងារអ្វីក៏ដោយ។ បុគ្គលិកបរទេសត្រូវមានលិខិតអនុញ្ញាតឲ្យធ្វើការងារពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ១៨:**

បំពេញការងារដោយពិគ្រោះយោបល់ និងសហការឲ្យបានជិតស្និទ្ធជាមួយស្ថាប័នរដ្ឋាភិបាលដែលជាដៃគូ និងអាជ្ញាធរមូលដ្ឋាន ដើម្បីអនុវត្តគម្រោង ឬកម្មវិធីនានា ដែលបានអនុញ្ញាត ។ ជាពិសេស ត្រូវជូនដំណឹងទៅដៃគូ នៅពេលចាត់តាំងបុគ្គលិកជំនាញឲ្យទៅធ្វើការនៅការដ្ឋាន ឬក៏ស្នើសុំពន្យាពេលសុពលភាពទិដ្ឋាការសំរាប់បុគ្គលិកជំនាញដើម្បីបំពេញការងារ ។

**ប្រការ ១៩:**

យល់ព្រមថា បុគ្គលិកក្នុងស្រុក និងបុគ្គលិកបរទេសត្រូវដាក់ឲ្យស្ថិតក្រោមបទបញ្ញត្តិស្តីពីពន្ធលើប្រាក់បៀវត្ស និងពន្ធអាករផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានការសំរេចផ្សេងរបស់រាជរដ្ឋាភិបាល ។

អង្គការ **Kidshelp Kambodscha e.V** យល់ព្រមគោរពកាតព្វកិច្ចសារពើពន្ធស្របទៅតាមច្បាប់ និងបទបញ្ញត្តិនានាស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ។

## ផ្នែកទី បួន

## អវសានបញ្ញត្តិ

**ប្រការ ២០:**

នាយកឬតំណាងអង្គការ **Kidshelp Kambodscha e.V** ប្រចាំប្រទេសកម្ពុជា ឬតំណាង ដែលត្រូវបានទទួលការតែងតាំងជាផ្លូវការផ្សេងទៀតរបស់អង្គការនេះត្រូវបានទទួលស្គាល់ឲ្យធ្វើសកម្មភាពក្នុងនាមអង្គការ **Kidshelp Kambodscha e.V** ជាមួយរាជរដ្ឋាភិបាលកម្ពុជាក្រោយពេលចុះហត្ថលេខាលើអនុស្សរណៈនេះ។

**ប្រការ ២១:**

អង្គការ **Kidshelp Kambodscha e.V** អាចផ្អាកសកម្មភាព បានដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ មុនផ្អាកសកម្មភាព អង្គការ **Kidshelp Kambodscha e.V** ត្រូវធ្វើរបាយការណ៍បូកសរុបការងារ និងរបាយការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុងប្រការ១៣ នៃអនុស្សរណៈនេះ។

អង្គការ **Kidshelp Kambodscha e.V** មុននឹងបញ្ចប់សុពលភាពត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន។

អង្គការ **Kidshelp Kambodscha e.V** ត្រូវចាត់ចែងធនធាន និងទ្រព្យសម្បត្តិ ដែលនៅសល់ពីការជម្រះកាតព្វកិច្ច ដោយអនុលោមតាមកិច្ចព្រមព្រៀងជាមួយម្ចាស់ជំនួយ។

**ប្រការ ២២:**

រាជរដ្ឋាភិបាលអាចបញ្ចប់សុពលភាពអនុស្សរណៈ ក្នុងករណីអង្គការ **Kidshelp Kambodscha e.V** អនុវត្តមិនបានត្រឹមត្រូវតាមអនុស្សរណៈ ឬ ក្នុងករណីអង្គការ **Kidshelp Kambodscha e.V** ធ្វើសកម្មភាពប៉ះពាល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬ បង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមកម្ពុជា ។

ក្នុងករណីដែលអង្គការ **Kidshelp Kambodscha e.V** ធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខជាតិ ឬមានការពាក់ព័ន្ធនឹងការសម្អាតប្រាក់ហិរញ្ញប្បទានភេរវកម្ម ឬបទល្មើសភេរវកម្ម ឬបទល្មើសព្រហ្មទណ្ឌផ្សេងទៀតត្រូវផ្តន្ទាទោស ដោយយោងតាមបទប្បញ្ញត្តិច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២៣:**

ក្នុងករណីអង្គការ **Kidshelp Kambodscha e.V** មិនបានអនុវត្តតាមប្រការ ១១ ១៣ និង១៤ នៃអនុស្សរណៈនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយទុករយៈពេលយ៉ាងយូរ៣០ (សាមសិប)ថ្ងៃ។ ក្នុងករណីមិនអនុវត្ត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវព្រមានលាយលក្ខណ៍ អក្សរដោយទុករយៈពេលយ៉ាងយូរ៣០ (សាមសិប) ថ្ងៃ។ ក្នុងករណីនៅតែមិនព្រមអនុវត្តតាមការព្រមាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រេចជាលាយលក្ខណ៍អក្សរបញ្ចប់សុពលភាពអនុស្សរណៈ។

**ប្រការ ២៤:**

អនុស្សរណៈនេះអាចបញ្ចប់បានដោយភាគីណាមួយ បន្ទាប់ពីបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ផ្ញើជូនភាគីម្ខាងទៀត ។ ក្នុងករណីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រេចបញ្ចប់សុពលភាពអនុស្សរណៈរបស់អង្គការមុនកាលកំណត់ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់អង្គការ **Kidshelp Kambodscha e.V** ដែលបានស្នើសុំបើកទីស្នាក់ការតំណាងនៅកម្ពុជា។

**ប្រការ ២៥:**

អនុស្សរណៈនេះចូលជាធរមានចាប់ពីពេលចុះហត្ថលេខាដោយភាគីទាំងពីរ និងមានសុពលភាពរយៈពេលយ៉ាងយូរ ៣ (បី) ឆ្នាំ ព្រមទាំងអាចបន្តសុពលភាពបាន ដោយមានការយល់ព្រមពីភាគីទាំងពីរ។ សុពលភាពអនុស្សរណៈនេះ នឹងត្រូវបញ្ចប់ជាស្វ័យប្រវត្តិក្រោយថ្ងៃផុតកំណត់។

ការសុំបន្តសុពលភាពអនុស្សរណៈនេះ ត្រូវធ្វើឡើងឲ្យបាន៩០(កៅសិប)ថ្ងៃ មុនថ្ងៃផុតសុពលភាពអនុស្សរណៈ។

**ប្រការ ២៦:**

អនុស្សរណៈធ្វើជាពីរច្បាប់ដើម ជាភាសាខ្មែរ និងអង់គ្លេស ដោយអត្ថបទទាំងពីរមានតំលៃស្មើគ្នា ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៩

**ជួសមុខរាជរដ្ឋាភិបាល**

**លុយ ដាវីត**
**រដ្ឋលេខាធិការ**

**ជួសមុខអង្គការ KIDSHELP KAMBODSCHA E.V**

**MICHEL DOHR**
**COUNTRY DIRECTOR**

## ឧបសម្ព័ន្ធនៃអនុស្សរណៈ

- <u>អង្គការមិនមែនរដ្ឋាភិបាលបរទេស</u>៖ សំដៅដល់អង្គការស្របច្បាប់ដែលបង្កើតឡើងនៅក្រៅប្រទេសក្នុងគោលបំណងធ្វើសកម្មភាពដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយមិនទាញយកចំណេញ។

- <u>ចំណាយរដ្ឋបាល</u>៖ ជាការចំណាយលើដំណើរការងាររដ្ឋបាល និងប្រាក់បៀវត្សបុគ្គលិករដ្ឋបាល និងនាយក ។

- <u>បុគ្គលិកជំនាញ</u>៖ ជាអ្នកជំនាញការបច្ចេកទេស និងទីប្រឹក្សាបច្ចេកទេស ។

- <u>ជនអន្តោប្រវេសន៍</u>៖ ជាជនបរទេសដែលមកដល់កម្ពុជាដោយស្របច្បាប់ ដើម្បីស្នាក់នៅរយៈពេលយូរ ឬ ដើម្បីប្រកបវិជ្ជាជីវៈ ឬធ្វើសកម្មភាពផ្សេងៗទាក់ទងនឹងឧស្សាហកម្ម សេវាកម្ម ឬកសិកម្ម ។